ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៨៧ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឱ្យអនុវត្តសាកល្បងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅរដ្ឋបាលក្រុង ស្រុកនៃខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីប័ណ្ណព្រំដែនកម្ពុជា-ថៃ
- បានឃើញកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



ៗ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅរដ្ឋបាលក្រុង ស្រុក នៃខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃសម្រាប់រយៈពេល ០៦ខែ ដោយគិតចាប់ពីថ្ងៃទី**០១** ខែ**មករា ឆ្នាំ២០២៤**។

ក្នុងរយៈពេលអនុវត្តសាកល្បងនេះ អភិបាលក្រុង ស្រុកនៃខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃត្រូវបានធ្វើប្រតិភូកម្មអំណាចឱ្យ ក្នុងការពិនិត្យ សម្រេច និងចុះហត្ថលេខាលើប័ណ្ណព្រំដែនកម្ពុជា-ថៃជូនប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងការអនុវត្តសាកល្បងនេះនឹងត្រូវបន្តដោយស្វ័យប្រវត្តិ ប្រសិនបើពុំមានការសម្រេចផ្សេងណាមួយពីរាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ២.-**

រដ្ឋបាលក្រុង ស្រុកដូចមានចែងក្នុងមាត្រា១ នៃសេចក្តីសម្រេចនេះត្រូវរៀបចំការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃជូនប្រជាពលរដ្ឋខ្មែរ តាមរយៈការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក និងទីតាំងផ្សេងទៀតតាមការចាំបាច់ដែលកំណត់ដោយរដ្ឋបាលក្រុង ស្រុកសាមី ដោយប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវាក្នុងអង្គភាពច្រកចេញចូលតែមួយ និងប្រព័ន្ធគ្រប់គ្រងប័ណ្ណព្រំដែនកម្ពុជា។

**ប្រការ៣.-**

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃជូនប្រជាពលរដ្ឋខ្មែរនៅរដ្ឋបាលក្រុង ស្រុក ត្រូវអនុលោមតាមប្រកាសលេខ ១៤៧៧ ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ។

**ប្រការ៤.-**

តម្លៃសេវា និងរយៈពេលអតិបរមានៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ ត្រូវអនុលោមតាមប្រកាសអន្តរក្រសួងលេខ ៣៤៩៤ ប្រក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបន្ថែមសេវាផ្តល់ប័ណ្ណព្រំដែនលើតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលក្រុង ស្រុកនៃខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអំពីតម្លៃសេវា និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែននេះ។

**ប្រការ៥.-**

រដ្ឋបាលខេត្តពាក់ព័ន្ធត្រូវរៀបចំគម្រោងចំណូលពីកម្រៃសេវាផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។



០៤

ចំណូលប្រមូលបានពីកម្រៃសេវាផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ រដ្ឋបាលក្រុង ស្រុកត្រូវរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីកត់ត្រាជាចំណូលរបស់រដ្ឋបាលខេត្តសាមីដែលមានការពាក់ព័ន្ធ។

**ប្រការ៦.-**

ចំណូលដែលប្រមូលបានពីសេវាផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ត្រូវចាត់ចែង និងបែងចែកតាមគោលការណ៍ដែលមានចែងក្នុងប្រកាសអន្តរក្រសួង ៣៤៩៥ ប្រក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាផ្តល់ប័ណ្ណព្រំដែន។

ថវិការង្វាន់របស់រដ្ឋបាលខេត្តដែលប្រមូលបានពីការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃនៅរដ្ឋបាលក្រុង ស្រុកនីមួយៗ ត្រូវបែងចែកដល់រដ្ឋបាលក្រុង ស្រុកសាមីចំនួន ៨៥% ផ្អែកតាមទំហំសេវាដែលរដ្ឋបាលក្រុង ស្រុកនីមួយៗបានផ្តល់ និងរក្សាទុកនៅរដ្ឋបាលខេត្តចំនួន ១៥%។

**ប្រការ៧.-**

ក្រសួងមហាផ្ទៃត្រូវចាត់ចែងការងារដូចខាងក្រោម៖

- រៀបចំ និងផ្តល់ការគាំទ្រដល់ការបំពាក់ឧបករណ៍ និងសម្ភារនានាជូនរដ្ឋបាលក្រុង ស្រុកនៃខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃសម្រាប់បម្រើឱ្យការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ
- ត្រូវផ្តល់ការបណ្តុះបណ្តាល និងផ្តល់ការគាំទ្រនានាដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុកនៅក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃជូនប្រជាពលរដ្ឋខ្មែរ
- បែងចែកប័ណ្ណព្រំដែនកម្ពុជា-ថៃក្នុងបរិមាណសមស្របជូនដល់រដ្ឋបាលក្រុង ស្រុកនីមួយៗដោយផ្អែកតាមស្ថានភាព និងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុកសាមី
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃដោយរដ្ឋបាលក្រុង ស្រុកក្នុងរយៈពេលនៃការអនុវត្តសាកល្បងនេះ និងរាយការណ៍អំពីលទ្ធផលនៃការអនុវត្តសាកល្បងជូនប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៨.-**

រដ្ឋបាលខេត្តត្រូវផ្តល់កិច្ចសហការ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុកក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ ព្រមទាំងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការផ្តល់សេវាប័ណ្ណព្រំដែននេះ។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់



ﻑ

ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃ ពុធ ១០ កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ